**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ១៤រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់ព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៩ វេលាម៉ោង ០៩ : ០០ នាទីព្រឹក, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង និងតំណាងពីគ្រប់អង្គភាពថវិកា ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានក្រោមឱវាទក្រសួង ។ ការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ៗ ៣ គឺ÷

១. តាមដាន និងរាយការណ៍ អំពីវឌ្ឍនភាពដែលអង្គភាពក្រោមឱវាទក្រសួង បានសម្រេចប្រចាំឆ្នាំ ដោយផ្តោតសំខាន់លើទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម,

២. កំណត់បញ្ហាប្រឈម និង ស្នើដាក់ចេញនូវវិធានការដោះស្រាយ ដើម្បីជំរុញការអនុវត្តការងារសម្រាប់ឆ្នាំបន្តបន្ទាប់ ឱ្យកាន់តែរលូន និងសម្រេចបានតាមគោលដៅ,

៣. បំពេញតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិគតិយុត្តជាធរមាន ពាក់ព័ន្ធថវិកាកម្មវិធី ។

ជាលទ្ធផល, ការត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ ២០១៨÷

- ចំពោះទិដ្ឋភាពហិរញ្ញវត្ថុផ្នែកចំណូល សម្រាប់គម្រោងកញ្ចប់ថវិកាឆ្នាំ ២០១៨ គឺ ឥណទានចំណូលកើនឡើងចំនួន ១២,២% ធៀបច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧ ។ ការប្រមូលចំណូលរបស់ក្រសួង ជារួម (មិនគិតចំណូលពន្ធដារថ្នាក់ក្រោមជាតិ) សម្រេចបាន ១១០,៤% ធៀបច្បាប់ ក្នុងនោះថ្នាក់កណ្តាលសម្រេចបាន ១១០,៤% ធៀបច្បាប់ រីឯថ្នាក់មូលដ្ឋានសម្រេចបាន ៩៩,៤% ធៀបច្បាប់ ។
- ទិដ្ឋភាពហិរញ្ញវត្ថុផ្នែកចំណាយវិញ គឺការអនុវត្តចំណាយមានចំនួន ១០៤,៣% (តួលេខអាណត្តិទូទាត់) នៃច្បាប់ដើមឆ្នាំ ឬ ស្មើនឹង ៩៥,៨% នៃឥណទានថ្មី ហើយសម្រាប់ការអនុវត្តចំណាយនៅតាមអង្គភាពថវិកា ឃើញថាការអនុវត្តប្រចាំឆ្នាំ ២០១៨ មានការវិវត្តល្អមួយកម្រិត បើធៀបនឹងការអនុវត្តថវិកានាបណ្តាឆ្នាំកន្លងមក ទាំងសម្រាប់រដ្ឋបាលកណ្តាល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ។
- ទិដ្ឋភាពសមិទ្ធកម្មប្រចាំឆ្នាំ ២០១៨ ធៀបទៅនឹងសូចនាករដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ជារួម សម្រេចបានប្រមាណ ៩៤% ក្នុងនោះ គោលបំណងគោលនយោបាយទី ១ (ពង្រឹងនិង

បង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងសេដ្ឋកិច្ចនិងអភិវឌ្ឍវិស័យហិរញ្ញវត្ថុ) សម្រេចបាន ៩៤% និងគោលបំណងគោលនយោបាយទី ២ (ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ) សម្រេចបាន ៩៥% ហើយសមិទ្ធកម្មតាមអនុកម្មវិធី/អង្គភាពថវិកាភាគច្រើនសម្រេចលទ្ធផលល្អលើសពី ៨៩%។

ជារួម សម្រាប់ឆ្នាំ ២០១៨ លទ្ធផលប្រមូលចំណូលជាក់ស្តែងបានអនុវត្តក្នុងកម្រិតល្អ ។ ចំណែក ការអនុវត្តចំណាយក៏កាន់តែមានភាពប្រសើរជាងមុន ។ ជាមួយគ្នានេះ ការអនុវត្តសកម្មភាព សម្រេចបានសមិទ្ធកម្មសំខាន់ៗជាច្រើន នៅគ្រប់កម្មវិធី ខិតជិតគោលដៅកំណត់ក្នុងផែនការ ។ ប៉ុន្តែ ទោះយ៉ាងណា ការទូទាត់ចំណាយតាមខែនៅពុំទាន់មានសង្គតិភាព នៅឡើយ ដោយអាណត្តិភាគច្រើនបង្គរនៅចុងឆ្នាំ ស្របពេលដែលគុណភាពនៃការគ្រោងថវិកានៅមានកម្រិត ដែលស្តែងចេញតាមរយៈការស្នើសុំធ្វើចលនាឥណទានច្រើនដង ។

ផ្អែកលើលទ្ធផលជាវិជ្ជមាននៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ ២០១៨ នេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន និងកំពុងអនុវត្ត ក្នុងការកសាង និងស្ថាបនាជាគំរូក្នុងការអនុវត្តថវិកាកម្មវិធី ដើម្បីជំរុញការអនុវត្តថវិកាកម្មវិធីឱ្យកាន់តែរលូន ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងអនុលោមតាមបទដ្ឋានគតិយុត្តជាធរមាន ។